អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប
International School of Siem Reap

# THE HIGH SCHOOL NEWSLETTER

ISSUE | 20 | AUGUST | 2022













## សូមស្វាគមន៍មកកាន់ សាលាអន្តរជាតិ ISSR

ថ្ងៃចូលរៀនដំបូងរបស់សិស្សានុសិស្សសាលាអន្តរជាតិ ISSR ក្នុងឆ្នាំសិក្សាថ្មីនេះបានប្រព្រឹត្តិទៅយ៉ាងរលូនជាមួយនឹងអារម្មណ៍រំភើបរីករាយស្និតស្នាលយ៉ាងក្រៃលែង ដោយមានការរង់ចាំទទួលស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់នាយិការប្រតិបត្តិកម្មវិធីអន្តរជាតិ និងបុគ្គលិករបស់សាលាISSR នៅច្រកទ្វាចូលសាលារៀន ។ សិស្សានុសិស្សបានជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូបន្ទុកថ្នាក់ថ្មីរបស់ពួកគេ ហើយបន្ទាប់មកពួកគេក៏បានចូលរួមកម្មវិធីប្រជុំដើម្បីទទួលការណែនាំពីគណៈគ្រប់គ្រងសាលា ។

ក្នុងកិច្ចប្រជុំនោះផងដែរ សិស្សានុសិស្សបានសម្ដែងពីទឹកចិត្តអរគុណដល់បុគ្គលិករបស់សាលាISSR ដែលបានខិតខំប្រឹងប្រែងរៀបចំរាល់កិច្ចការផ្សេងៗដើម្បីទទួលស្វាគមន៍នូវការវិលត្រឡប់មកវិញរបស់ពួកគេនាថ្ងៃនេះបានយ៉ាងល្អប្រសើរ ។ បន្ទាប់ពីបានស្ដាប់ការណែនាំនូវបទបញ្ញត្តិ និងវឌ្ឍនៈភាពទូទៅ របស់សាលាចប់ សិស្សានុសិស្សរបស់យើងបានជួបសំណេះសំណាលជាមួយមិត្តរួមថ្នាក់ថ្មីៗរបស់ពួកគេផងដែរ ។ ជាចុងបញ្ចប់នៃកម្មវិធីប្រជុំ គណៈគ្រប់គ្រងសាលាបានផ្ដល់ដំណឹងល្អបន្ថែមអំពីឱកាសក្លាយខ្លួនជាអ្នកដឹកនាំរបស់តំណាងយុវជន (SRC) ហើយក៏បានណែនាំឱ្យសិស្សានុសិស្សចេះគោរពវិន័យ លោកគ្រូ អ្នកគ្រូ បុគ្គលិកសាលា និងមិត្តទាំងអស់របស់ពួកគេផងដែរ ។



## WELCOME BACK TO ISSR

For the first day of school, students were greeted at the gate by our principal and staff, spent time with their newly assigned tutor teacher, and we conducted our first assembly for the start of this academic school year.

During assembly, students thanked ISSR staff for all the preparations made for the opening of school, welcomed new staff members and students, were reminded of general school rules, changes that have been made during the holidays, encouraged to join the Student Representative Council (SRC) and Extracurricular Activities (ECA), as well as being kind and respectful to all.